# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## យុទ្ធនាការអប់រំសុខភាព រួមគ្នាទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ក្រោមប្រធានបទ « រួមគ្នាប្រយុទ្ធវីរុសកូវីដ-១៩ បំប្លែងថ្មីអូមីក្រុង ដែលឆ្លងលឿនខ្លាំងជាងមុន អាចបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរដល់ អ្នក និងគ្រួសារ »

ក្រសួងសុខាភិបាល តាមរយៈអនុគណៈកម្មការអប់រំ បណ្តុះបណ្តាលនិងទំនាក់ទំនងសាធារណៈ នៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានចាប់ផ្តើមយុទ្ធនាការជាតិអប់រំសុខភាពរួមគ្នាទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ក្រោមប្រធានបទ « *រួមគ្នាប្រយុទ្ធវីរុសកូវីដ-១៩ បំប្លែងថ្មីអូមីក្រុង ដែលឆ្លងលឿនខ្លាំងជាងមុន អាចបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរដល់អ្នក និងគ្រួសារ* » ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ក្នុងក្របខណ្ឌទូទាំងប្រទេសកម្ពុជា ក្នុងគោលបំណងដើម្បីក្រើនរំលឹក ពញ្ញាក់ស្មារតី និងបង្កើនជំរុញការចូលរួមរបស់បុគ្គល គ្រួសារ និងសហគមន៍ ព្រមទាំងបងប្អូនប្រជាពលរដ្ឋ ស្ថាប័ន-ក្រសួងពាក់ព័ន្ធ អង្គភាពសាធារណៈដទៃទៀត អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ មន្ទីរ អង្គភាពជំនាញនានា អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសេវាឯកជនទាំងអស់ ពួតដៃគ្នា បន្តអនុវត្តវិធានការចាំបាច់ៗនានា ដែលបានដាក់ចេញដោយការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការពង្រឹងការអនុវត្តវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃវីរុសកូវីដ-១៩ ជាពិសេសវីរុសបំប្លែងថ្មីប្រភេទ "*អូមីក្រុង*"។

ប្រទេសកម្ពុជាយើងបានបើកដំណើរការឡើងវិញនូវសកម្មភាពសេដ្ឋកិច្ច និងសង្គមនានាតាំងពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ប៉ុន្តែតាមការអង្កេតតាមដានរបស់អង្គការសុខភាពពិភពលោក បង្ហាញថា ជំងឺរាតត្បាតកូវីដ-១៩ នេះ បើទោះបីជានៅកម្រិតសកលលោកមានការថយចុះខ្លះៗ ក៏ប៉ុន្តែការរាតត្បាតជំងឺកូវីដ-១៩ បាននឹងកំពុងបន្តវាយលុកខ្លាំងនៅក្នុងបណ្តាប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិចនៅឡើយ ក្នុងនោះក៏មានប្រទេសកម្ពុជាយើងផងដែរ ដែលជាកង្វល់នៃការដែលអាចមានការរាតត្បាតទ្រង់ទ្រាយធំឡើងវិញ ដោយសារតែការចរាចរយ៉ាងទូលំទូលាយនៃវីរុសបំប្លែងថ្មីប្រភេទអូមីក្រុង **(Omicron)** ឆ្លងរាលដាលក្នុងល្បឿនមួយលឿនជាងវីរុសកូវីដ-១៩ បំប្លែងថ្មីប្រភេទមុនៗ ហើយក៏ជាប្រភេទវីរុសកូវីដ-១៩ ដែលសកលលោកទាំងមូលទទួលស្គាល់ថាងាយឆ្លងបំផុតនាពេលបច្ចុប្បន្ននេះ គួបផ្សំទៅនឹងការខ្វះចន្លោះនៃការអនុវត្តន៍វិធានការមិនប្រើឱសថ (Non-Pharmaceutical Interventions (NPIs)) រួមផ្សំនិងប្រជាពលរដ្ឋមួយចំនួនហាក់ធ្វេសប្រហែស ភ្លេចខ្លួនក្នុងការអនុវត្តវិធានការសុខាភិបាលត្រឹមត្រូវ និងហ្មត់ចត់ ដែលជាឱកាសដ៏ល្អសម្រាប់វីរុសកូវីដ-១៩ ធ្វើចរាចរយ៉ាងសកម្ម បង្កឱ្យមានការចម្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍។ ជាក់ស្តែងចាប់តាំងពី "*អូមីក្រុង*" ចូលមកប្រទេសកម្ពុជាយើងតាំងពីពាក់កណ្តាលខែធ្នូ ឆ្នាំ២០២១ មកដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ នេះ ករណីឈឺ និងស្លាប់ នៅតែរកឃើញមានជាបន្តបន្ទាប់រៀងរាល់ថ្ងៃ ដែលធ្វើឱ្យមានកំណើនសរុបនៃករណីឈឺ និងស្លាប់នៅកម្ពុជា ហើយហានិភ័យនៃការកើនឡើងនៃករណីជំងឺកូវីដ-១៩ ដោយសារតែវីរុសកូវីដ-១៩ ប្រភេទ "*អូមីក្រុង*" គឺប្រហែលជាមានខ្ពស់ នៅក្នុងចំណោមសហគមន៍ ដោយសារ



ទីស្តីការក្រសួងសុខាភិបាលដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ពួកគាត់បានធ្វើតេស្តរហ័ស និងស្នាក់នៅព្យាបាលនៅតាមផ្ទះដោយខ្លួនឯង។ នេះមានន័យថា ជំងឺរាតត្បាតកូវីដ-១៩ នៅឆ្ងាយពីទីបញ្ចប់ ហើយជាក់ស្តែង គិតចាប់ពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ កម្ពុជាបានរកឃើញអ្នកមានវិជ្ជមានវីរុសកូវីដ-១៩ ប្រភេទ *"អូមីក្រុង"* សរុបទាំងអស់ចំនួន ១៣.៥៦១ នាក់ និងមានអ្នកស្លាប់បាត់បង់ជីវិតដោយសារអូមីក្រុង ចំនួន ៥១នាក់ រួចទៅហើយ។ យោងតាមលទ្ធផលខាងលើបង្ហាញឱ្យយើងឃើញថា ប្រសិនបើបុគ្គលនៅតែបន្តមានការធ្វេសប្រហែសវីរុស *"អូមីក្រុង"* និងបន្តរាតត្បាតវាយលុកចូលក្នុងសហគមន៍របស់យើង ដែលទាមទារឱ្យមានវិធានការរួមផ្សំគ្នាជាច្រើន និងទាមទារឱ្យមានការរួបរួមគ្នា ដើម្បីអាចទប់ស្កាត់ការចម្លងនេះបាន។

ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមអំពាវនាវយ៉ាងឱឡារិកដល់សាធារណជន និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ដូចតទៅ៖

**ក. សម្រាប់បុគ្គល គ្រួសារ និងបងប្អូនប្រជាពលរដ្ឋទាំងអស់នៅទូទាំងប្រទេសកម្ពុជា៖**

- សូមចូលរួមបន្តអនុវត្តវិធានការបង្ការជំងឺ "**៣ការពារ**" បូកនិង "**ចាក់វ៉ាក់សាំងកូវីដ-១៩**" នៅពេលដល់វេនរបស់លោកអ្នក ទាំងការចាក់ដូសមូលដ្ឋាន ទាំងការចាក់ដូសទី៣ ឬដូសជំរុញ ឬចាក់ដូសទី៤ និងចំពោះវ៉ាក់សាំង **ចនសុនចនសុន** ត្រូវចាក់ដូសជំរុញឱ្យបានគ្រប់ៗគ្នា ហើយត្រូវបន្តអនុវត្តវិធានការ "**៣កុំ**" ឱ្យបានល្អ ឱ្យទៅជាការអនុវត្តជាក់ស្តែងជាប្រចាំ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយផ្តើមចេញពីបុគ្គលផ្ទាល់ខ្លួនម្នាក់ៗ សមាជិកគ្រួសារ សហគមន៍ ម្ចាស់ទីតាំងនានា និងសង្គមទាំងមូល ដែលអនុញ្ញាតឱ្យយើងទាំងអស់គ្នា អាចនៅតែបន្តអាជីវកម្មនិងប្រកបការងារលើគ្រប់វិស័យទាំងអស់ ព្រមទាំងអាចដំណើរការឡើងវិញបាននូវការរស់នៅជាធម្មតាក្នុងប្រក្រតីភាពថ្មីប្រចាំថ្ងៃមាននិរន្តរភាព ហើយប្រជាពលរដ្ឋក៏អាចប្រកបរបររកស៊ីទទួលទានចិញ្ចឹមជីវិតឡើងវិញប្រកបដោយសុវត្ថិភាព នៅក្នុងបរិបទរៀនរស់ជាមួយនឹងវីរុសកូវីដ-១៩ តាមបែបរស់នៅធម្មតាក្នុងប្រក្រតីភាពថ្មី។

  សូមក្រើនរំលឹកឡើងវិញ ដូចខាងក្រោម៖

  **៣ការពារ ៖**

  ១). ពាក់ម៉ាស់ ៖ ជាពិសេសនៅពេលកំពុងពាក់ម៉ាស់ សូមកុំយកដៃប៉ះផ្ទៃមុខនៃម៉ាស់ ឬទាញម៉ាស់ដាក់ក្រោមចង្ការ និងត្រូវដូរម៉ាស់ថ្មី នៅពេលវាសើម។

  ២). លាងដៃឱ្យបានញឹកញាប់ ជាមួយសាប៊ូ និងទឹកស្អាត ក្នុងរយៈពេល ៤០វិនាទី ឬជាមួយអាល់កុល ដែលក្នុងរយៈពេល ២០វិនាទី។

  ៣). រក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង៖ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគម្លាតសុវត្ថិភាពបុគ្គលនេះ បើទោះបីជាបងប្អូន សមាជិកគ្រួសារ ឬសាច់ញាតិ ដែលពួកគាត់មានការស្នាក់នៅក្នុងគេហដ្ឋានផ្សេងពីលោកអ្នក ឬក៏មិត្តភ័ក្រ្តជិតស្និទ្ធក៏ដោយ។

  **៣កុំ ៖**

  ១). កុំទៅកន្លែងមានមនុស្សច្រើន និងកន្លែងណែនកុះករកៀកៗគ្នា ក្នុងន័យនេះរាប់ទាំងការជួបជុំពិសារអាហារជាលក្ខណៈក្រុមគ្រួសារជាមួយសាច់ញាតិដែលមានការស្នាក់នៅក្នុងគេហដ្ឋានផ្សេងពីអ្នក ឬមិត្តភ័ក្រ្តជិតស្និទ្ធ ក្នុងទ្រង់ទ្រាយធំច្រើនគ្នាពេក ជាដើម។

  ២). កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើន។

  ៣). កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា ពេលជួបភ្ញៀវ សូម្បីតែសមាជិកគ្រួសារ សាច់ញាតិ ដែលមានការស្នាក់នៅក្នុងគេហដ្ឋានផ្សេងពីលោកអ្នក ឬ មិត្តភ័ក្រ្តជិតស្និទ្ធ ជាដើម។

- សូមចូលរួមជំរុញ ក្រើនរំលឹក និងតាមដានដាស់តឿន បុគ្គលខ្លួនឯង សមាជិកគ្រួសារ សាច់ញាតិ អ្នកជិតខាង អ្នកភូមិជាមួយ និងសហគមន៍ជាមួយ ឱ្យអនុវត្តជាប្រចាំថ្ងៃ ឱ្យបានខ្ជាប់ខ្ជួននូវ " ៣ការពារ និង៣កុំ " និងនាំគ្នាទៅចាក់វ៉ាក់សាំងទាំងដូសមូលដ្ឋាន និងដូសទី៣ ឬដូសជំរុញ ឱ្យបានគ្រប់ៗគ្នា ដូចបានរៀបរាប់ខាងលើ។

- សូមចូលរួម តាមដាន និងរាយការណ៍ជាបន្ទាន់ជូនដល់អាជ្ញាធរមូលដ្ឋាន ចំពោះអ្នកធ្វើតេស្តរហ័សឃើញវិជ្ជមានវីរុសកូវីដ-១៩ ដែលទាមទារឱ្យមានការប្រកាន់ខ្ជាប់នូវការធ្វើចត្តាឡីស័ក និងដាក់ខ្លួនឱ្យនៅដាច់ដោយឡែក ឱ្យបានពេញលេញ និងត្រឹមត្រូវគ្រប់ពេលវេលា ទៅតាមការណែនាំរបស់គ្រូពេទ្យ និងអាជ្ញាធរមានសមត្ថកិច្ច។
- សូមចូលរួមផ្តល់ការអប់រំ និងចែករំលែកនូវចំណេះដឹងដែលខ្លួនបានដឹង និងចេះបន្តដល់សមាជិកគ្រួសារ សាច់ញាតិ អ្នកជិតខាង អ្នកភូមិជាមួយ និងសហគមន៍ជាមួយ ដើម្បីអនុវត្តទាំងអស់គ្នា។
- សូមចូលរួម និងរួបរួមគ្នា សហការគ្នា ជាមួយអាជ្ញាធរមូលដ្ឋាន រកដំណោះស្រាយក្នុងតំបន់ ដើម្បីដោះស្រាយបញ្ហាដែលកើតមាននៅក្នុងសហគមន៍របស់ខ្លួនទាក់ទងនឹងការអនុវត្តន៍ " ៣ការពារ និង៣កុំ" ឱ្យមានប្រសិទ្ធភាព។
- សូមចូលរួមអនុវត្តឱ្យបានតាមការណែនាំ និងវិធានការនានា ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងដោយរដ្ឋបាលរាជធានី-ខេត្ត ដើម្បីអនុញ្ញាតឱ្យយើងអាចគ្រប់គ្រងសភាពការណ៍បានល្អទាន់ពេលវេលា និងអាចបន្តអាជីវកម្ម ព្រមទាំងដំណើរការវិស័យទាំងអស់ឡើងវិញបានជាបន្ត ហើយប្រជាពលរដ្ឋអាចប្រកបរបរចិញ្ចឹមជីវិតឡើងវិញប្រកបដោយសុវត្ថិភាព នៅក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩ ទៅតាមបែបបទរស់នៅធម្មតាក្នុងប្រក្រតីភាពថ្មី និងប្រកបដោយនិរន្តរភាពយូរអង្វែង។

**ខ. សម្រាប់ស្ថាប័នពាក់ព័ន្ធនានា វិស័យឯកជន និងអង្គការជាតិ-អន្តរជាតិ ៖**

- សូមចូលរួមជួយគាំទ្រនូវសកម្មភាពរបស់យុទ្ធនាការជាតិនេះ ដោយបន្តធ្វើការផ្សព្វផ្សាយសារយុទ្ធនាការជាតិនេះជាប់ជាប្រចាំ តាមគ្រប់មធ្យោបាយដែលមាន ជូនដល់បុគ្គលិកនៃស្ថាប័នរបស់ខ្លួន។
- សូមធ្វើការតាមដានជាប្រចាំ និងឃ្លាំមើលនូវការអនុវត្តរបស់បុគ្គលិកដែលស្ថិតនៅក្រោមឱវាទស្ថាប័នរបស់ខ្លួន ព្រមទាំងរួមគ្នា រកដំណោះស្រាយនៅហ្នឹងកន្លែង ដើម្បីបន្តជំរុញនូវការអនុវត្តវិធានកាសុខាភិបាល និងអន្តរាគមន៍នានាប្រកបដោយប្រសិទ្ធភាព។
- សូមចូលរួម បន្តផ្តល់ការអប់រំ ជំរុញ ក្រើនរំលឹក និងដាស់តឿនជាប្រចាំដល់បុគ្គលិកដែលស្ថិតនៅក្រោមស្ថាប័នរបស់ខ្លួន អំពីការអនុវត្តន៍ "៣ការពារ និង៣កុំ" ឱ្យមានប្រសិទ្ធភាព និងជំរុញឱ្យមានការបើកបង្អួចឱ្យមានខ្យល់ចេញចូលនៅកន្លែងធ្វើការ ព្រមទាំងជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានគ្រប់ដូសមូលដ្ឋាន និងដូសជំរុញ។
- ផលិត និងបិទផ្ទាំងរូបភាពទាក់ទងទៅនឹងការបង្ការ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅក្នុងស្ថាប័នរបស់ខ្លួន។
- ចាក់មេក្រូផ្សព្វផ្សាយនូវសារអប់រំជាប្រចាំ នៅកន្លែងធ្វើការនីមួយៗ។

**គ. សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាន**

- បន្តការអប់រំផ្សព្វផ្សាយនៅតាមភូមិ ឃុំ ស្រុក ឱ្យបានផុសផុលនូវខ្លឹមសារយុទ្ធនាការជាតិ ដោយប្រើប្រាស់គ្រប់មធ្យោបាយដូចជា ចាក់មេក្រូតាមយានយន្ត ឬម៉ែក ឬម៉ូតូកង់បី ជាដើម ជាពិសេសជំរុញការការពារឱ្យបានហ្មត់ចត់ និងការអនុវត្តវិធានការ "**៣ការពារ + ៣កុំ + ចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងដូសទី៣ ឬដូសជំរុញ** នៅតាមសហគមន៍របស់ខ្លួនឱ្យបានគ្រប់ៗគ្នា។
- បន្តការអប់រំសុខភាព ជាពិសេសការការពារការចម្លងវីរុសកូវីដ-១៩ និងការនាំគ្នាទៅចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានគ្រប់ៗគ្នា និងឱ្យបានជាប់ជាប្រចាំ។
- ធ្វើជំរឿនអ្នកដែលមិនទាន់បានចាក់វ៉ាក់សាំង ឬមិនទាន់បានចាក់ដូសទី៣ ឬដូសជំរុញ ដោយសហការល្អជាមួយមន្ទីរសុខាភិបាលខេត្ត ឬស្រុកប្រតិបត្តិ ឬមណ្ឌលសុខភាព ដើម្បីរៀបចំក្រុមគ្រូពេទ្យចុះទៅចាក់ដល់ទីកន្លែងភូមិ ឬឃុំ ដោយធ្វើការកៀងគរប្រជាជនមកទទួលយកវ៉ាក់សាំងកូវីដ-១៩ ទៅតាមកាលបរិច្ឆេទកំណត់។
- តាមដានការអនុវត្តន៍របស់បងប្អូនប្រជាពលរដ្ឋនៅតាមភូមិ ឃុំ ស្រុករបស់ខ្លួន និងចាត់វិធានការសមស្របនូវសកម្មភាពសសកម្មណាមួយ ដែលធ្វើបង្កឱ្យមានការចម្លងបន្តនៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានទាន់ពេលវេលា។



ទីស្តីការក្រសួងសុខាភិបាលដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

– ត្រូវរាយការណ៍ឱ្យបានទាន់ពេលវេលា នូវហេតុការណ៍នៃការផ្ទុះឡើងនូវការចម្លងជំងឺកូវីដ-១៩ ឬជំងឺឆ្លងណាមួយ នៅក្នុងសហគមន៍របស់ខ្លួន ដើម្បីចាត់វិធានការសុខាភិបាលបានទាន់ពេលវេលា កាត់បន្ថយបានជាអតិបរិមានូវផលប៉ះពាល់ធំដល់សង្គមជាតិ។

ក្រសួងសុខាភិបាល គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងអនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ (អ.ប.ទ) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះការយកចិត្តទុកដាក់ចូលរួមផ្សព្វផ្សាយ ទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ របស់បុគ្គល គ្រួសារ និងសហគមន៍ និងបងប្អូនប្រជាពលរដ្ឋ ស្ថាប័នពាក់ព័ន្ធនានា វិស័យឯកជន អង្គការជាតិ-អន្តរជាតិ ព្រមទាំងរដ្ឋបាលរាជធានី-ខេត្តទាំងអស់ ដែលបានយកចិត្តទុកដាក់ចូលរួមធ្វើយុទ្ធនាការជាតិអប់រំសុខភាពការពារទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ខាងលើនេះ ហើយក៏សូមអំពាវនាវ សូមឱ្យមានការចូលរួមអនុវត្តតាមការណែនាំខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរួមចំណែកកាត់ផ្តាច់ខ្សែចម្លងវីរុសកូវីដ-១៩ និងការចម្លងវីរុសកូវីដ-១៩ ពីបុគ្គលម្នាក់ទៅម្នាក់ ជាពិសេសត្រូវចូលរួមបញ្ចៀសនូវការរាតត្បាតជាលក្ខណៈទ្រង់ទ្រាយធំ នៅក្នុងសហគមន៍នៃប្រទេសកម្ពុជា ដោយសារតែវីរុសបំប្លែងថ្មី "*អូមីក្រុង*" នេះ។

ថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២



ទីស្តីការក្រសួងសុខាភិបាលដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩